**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧០...អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតនាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ នៃក្រសួងសាធារណការនិងដឹកជញ្ជូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និង មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**មាត្រា១ .-**

បង្កើតនាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន បំពេញបន្ថែមអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២ .-**

នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែងដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ សាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿននិងស្ពានធំៗ
- កំណត់អត្តសញ្ញាណគម្រោងសាងសង់ផ្លូវល្បឿនលឿននិងស្ពានធំៗ
- រៀបចំគម្រោងកម្មវិធីអភិវឌ្ឍផែនការមេនិងវិនិយោគលើផ្លូវល្បឿនលឿននិងស្ពានធំៗ
- រៀបចំចងក្រងឯកសារនានាដែលពាក់ព័ន្ធនឹងបទដ្ឋានបច្ចេកទេស ការវិនិយោគ ការធ្វើលទ្ធកម្ម ការងារសម្បទាន ការគ្រប់គ្រងក្នុងវិស័យផ្លូវល្បឿនលឿននិងស្ពានធំៗ និងការសាងសង់គម្រោងផ្លូវល្បឿនលឿននិងស្ពានធំៗ
- សិក្សាប្លង់ស្ថាបត្យកម្មនិងវិស្វកម្មគម្រោងសាងសង់ផ្លូវល្បឿនលឿននិងស្ពានធំៗដែលវិនិយោគដោយវិស័យសាធារណៈនិងឯកជន
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការងារអនុវត្តគម្រោងសាងសង់ផ្លូវល្បឿនលឿននិងស្ពានធំៗតាមបទដ្ឋានបច្ចេកទេស
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគម្រោងសាងសង់ផ្លូវល្បឿនលឿននិងស្ពានធំៗដែលកំពុងដំណើរការឬបានបញ្ចប់ជាស្ថាពរតាមបទដ្ឋានបច្ចេកទេសនិងលើកសំណើសុំធ្វើការកែសម្រួលផែនការអនុវត្តគម្រោងក្នុងករណីចាំបាច់
- រៀបចំកម្មវិធីការងារថែទាំផ្លូវល្បឿនលឿននិងស្ពានធំៗដែលជាគម្រោងវិនិយោគសាធារណៈនិងវិនិយោគឯកជន
- តាមដាននិងត្រួតពិនិត្យការបម្រើសេវានិងសុវត្ថិភាពចរាចរណ៍
- ជំរុញកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មជាតិ តំបន់ អនុតំបន់ និងអន្តរជាតិលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿននិងស្ពានធំៗ
- ធ្វើរបាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស ៩(ប្រាំបួន)ខែ និងឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

**មាត្រា៣ .-**

នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ ដឹកនាំដោយប្រធាន ១(មួយ)រូប អមដោយអនុប្រធានជាជំនួយការអនុលោមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ មានការិយាល័យឬអង្គភាពជំនាញមួយចំនួនចំណុះ និងប្រើប្រាស់មន្ត្រីរាជការក្របខ័ណ្ឌដែលមានស្រាប់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន  រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ  រដ្ឋមន្ត្រីគ្រប់ក្រសួង  និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ  ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ